# ការបោះជំរំនៅក្នុងផ្ទះពេលថ្ងៃមានភ្លៀង



## ហេតុអ្វីព្រះវរបិតាសួគ៌មិនឆ្លើយតបនឹងការអធិស្ឋានរបស់នាង ?

ដោយ លូស៊ី ស្ទីវ៉ិនសុន អ៊ីវែល

*ដំណើររឿងពិតមកពី ស.រ.អា.*

« **កា**រប្រកួតរបស់ខ្ញុំគឺនៅថ្ងៃស្អែក ត្រូវទេ » ? លូស៊ីបានសួរ នៅពេលដែលម៉ាក់បានដណ្តប់ភួយឲ្យនាង ។

ម៉ាក់បានងក់ក្បាល ។ « ចា៎ស ! នៅថ្ងៃស្អែក ម៉ោង ៦:០០ ល្ងាច » ។

លូស៊ីស្ទើរតែពុំអាចរង់ចាំបាន ។ នាងបានទន្ទឹងរង់ចាំការប្រកួតកីឡា softball ដំបូងរបស់ក្រុមនាងអស់រយៈពេលជាច្រើនសប្តាហ៍មកហើយ ។ ហើយឆ្នាំនេះអាវកីឡារបស់ពួកគេគឺពណ៌ផ្កាឈូក ! នាងរំភើបរហូតដល់នាងពិបាកនឹងគេងលក់ ។

ប៉ុន្តែព្រឹកឡើង លូស៊ីបានសម្លឹងមើលទៅក្រៅបង្អួច ហើយបានជ្រួញចិញ្ចើម ។ មានពពកខ្មៅយ៉ាងអាប់អួនៅលើមេឃ ហើយមានទឹកដក់គ្រប់ទិសទីទៀត ។ មេឃបានភ្លៀងពេញមួយយប់ ។

នាងបានលុតជង្គង់ដើម្បីពោលពាក្យអធិស្ឋានពេលព្រឹករបស់នាង ។ « ឱ ព្រះវរបិតាសួគ៌ជាទីស្រឡាញ់ សូមទ្រង់មេត្តាជួយឲ្យអាកាសធាតុអំណោយផលដល់ការប្រកួតកីឡា softball របស់កូននៅល្ងាចនេះផង » ។

ពេញមួយថ្ងៃនៅសាលារៀន លូស៊ីបានគិតអំពីការប្រកួតនេះ ។ នាងបានស្រមៃឃើញខ្លួននាងពាក់អាវកីឡាពណ៌ផ្កាឈូកថ្មីរបស់នាង ឈោងដៃទៅចាប់បាល់ដើម្បីទទួលបានជ័យជម្នះ ។ ប៉ុន្តែនៅខាងក្រៅ នៅតែមានភ្លៀងធ្លាក់ ហើយសើមជាំដដែល ។

លូស៊ីបានធ្វើការអធិស្ឋានដ៏ខ្លីមួយនៅក្នុងគំនិតរបស់នាង ។ *ព្រះវរបិតាសួគ៌ ! សូមទ្រង់ជួយឲ្យមេឃបើកថ្ងៃឲ្យបានឆាប់ដើម្បីពួកយើងអាចប្រកួតបាននៅល្ងាចនេះ ។*

នៅពេលកណ្តឹងសាលាបានរោទិ៍ លូស៊ីបានចាប់យកកាបូបស្ពាយរបស់នាង ហើយរត់ទៅខាងក្រៅ ។ នាងអាចមើលឃើញព្រះអាទិត្យចាប់ផ្តើមលេចចេញពីខាងក្រោយដុំពពក !

ប៉ុន្តែពេលម៉ាក់មកទទួលនាង ម៉ាក់បានប្រាប់ដំណឹងអាក្រក់មួយ ។ ម៉ាក់បាននិយាយថា « ការប្រកួតយប់នេះគឺត្រូវបានលុបចោលហើយ » ។ « ម៉ាក់សូមទោស » ។

លូស៊ីបានសម្លឹងមើលមេឃ « ប៉ុន្តែ ចាប់ផ្តើមបើកថ្ងៃហើយតើ ! មេឃអាចនឹងឈប់ភ្លៀង » ។

ម៉ាក់បាននិយាយ « ម៉ាក់ដឹង » ។ « ប៉ុន្តែនៅទីលានកីឡា softball មានទឹកជន់ដោយសារតែទឹកភ្លៀង ។ ដូច្នេះទោះបីជារាំងភ្លៀងក្តី ក៏ទីលានសើមខ្លាំង ហើយមានភក់ មិនអាចលេងកីឡាបានទេ ។ ពួកគេនឹងដាក់កាលវិភាគការប្រកួតឡើងវិញនៅពេលក្រោយ » ។

លូស៊ីបានស្រក់ទឹកភ្នែក ។ នាងពិតជាខកចិត្តណាស់ ! នាងពិត *ជា* ចង់ប្រកួតនៅល្ងាចនេះខ្លាំងណាស់ ។ ហេតុអ្វីព្រះវរបិតាសួគ៌មិនឆ្លើយតបនឹងការអធិស្ឋានរបស់នាង ?

នៅផ្ទះ លូស៊ីមានអារម្មណ៍មិនសប្បាយចិត្ត ហើយមួម៉ៅដូចជាពពកដែលបង្អុរភ្លៀងដូច្នោះដែរ ។ នាងគ្មានអារម្មណ៍អានសៀវភៅដែលនាងចូលចិត្តនោះទេ ។ ហើយទោះបីជាម៉ាក់បានធ្វើផាស្តារដែលនាងចូលចិត្តញ៉ាំសម្រាប់អាហារពេលល្ងាចក៏ដោយ វាមិនមានរសជាតិឆ្ងាញ់ដូចរាល់ដងនោះដែរ ។

ក្រោយពីទទួលទានអាហារពេលល្ងាចរួច ប្អូនស្រីតូចរបស់លូស៊ី គឺ អែលី បានវារមកអង្គុយលើភ្លៅរបស់នាង ។ នាងបានសួរថា « តើបងនឹងលេងជាមួយខ្ញុំទេ » ?

លូស៊ីដកដង្ហើមធំ ។ នាងបានឆ្លើយ « ចាស » ។ បន្ទាប់មក នាងមានគំនិតមួយ « យើងត្រូវតែលេងអ្វីសប្បាយៗ » ។



នាងបានចាប់កាន់អំបោស ហើយចងកន្សែងនៅខាងចុងអំបោសនោះដើម្បីធ្វើជាទង់ជាតិ ។ បន្ទាប់មក នាងបានហៅប្អូនស្រីទាំងអស់របស់នាងមក ។ នាងបានលើកទង់ជាតិឡើង ហើយនិយាយថា « សូមស្វាគមន៍មកកាន់ការបោះជំរំនៅក្នុងផ្ទះពេលថ្ងៃមានភ្លៀង ! វាគឺជាការលេងសប្បាយៗជាមួយគ្នា នៅពេលដែលអ្នកមិនអាចចេញទៅលេងនៅខាងក្រៅបាន » ។

ប្អូនស្រីរបស់នាងបានហ៊ោឡើង ។

លូស៊ីបាននិយាយថា « ដំបូង » « យើងនឹងច្រៀងចម្រៀងសម្រាប់ការបោះជំរំរបស់យើងសិន » ។

ប្អូនស្រីរបស់នាងបានសើចកក្អឹក នៅពេលដែលពួកគេបង្កើតចម្រៀង និងពាក្យពេចន៍ដែលរឡេះរឡោះដើម្បីច្រៀងជាមួយគ្នា ។ បន្ទាប់មក ពួកគេបានដើរជុំវិញបន្ទប់ដោយមានទង់ជាតិរបស់ពួកគេ ដោយច្រៀងយ៉ាងឮៗតាមដែលពួកគេអាចធ្វើបាន ។

« ឥឡូវនេះ យើងត្រូវរៀបចំតង់របស់យើង ! » លូស៊ីបានជួយប្អូនស្រីរបស់នាងប្រមូលភួយ និងខ្នើយដើម្បីធ្វើជាបន្ទាយ ។ វាបានក្រឡាប់ពីរបីដង ។ ប៉ុន្តែនៅពេលដែលពួកគេដួសជុលវារួច ពួកគេទាំងអស់គ្នាបានប្រមូលផ្តុំគ្នានៅក្នុងបន្ទាយនោះដើម្បីលេងហ្គេម ។

មិនយូរប៉ុន្មានក៏ដល់ពេលចូលគេងហើយ ។ លីហ្សា ប្អូនស្រីរបស់លូស៊ី បាននិយាយថា « ខ្ញុំសង្ឃឹមថាមេឃនឹងភ្លៀងនៅថ្ងៃស្អែកម្តងទៀត » ។ « ខ្ញុំចង់លេងបោះជំរំនៅក្នុងផ្ទះពេលថ្ងៃមានភ្លៀងម្តងទៀត ! »

« អរគុណកូនដែលបានលេងជាមួយប្អូនស្រីរបស់កូន » ម៉ាក់បាននិយាយ ខណៈដែលគាត់ឱបលូស៊ី នៅពេលរៀបចំចូលគេង ។ « កូនបានធ្វើឲ្យមានរឿងល្អៗ ទោះបីជាកូនស្ថិតក្នុងស្ថានភាពដ៏អាប់អួក៏ដោយ ។ ម៉ាក់មានមោទនភាពចំពោះកូនណាស់ » ។

លូស៊ីមានអារម្មណ៍សប្បាយចិត្តពេលនាងឡើងទៅគេង ។ ការអធិស្ឋានរបស់នាងមិនបានទទួលការឆ្លើយតបតាមរបៀបដែលនាងចង់បាននោះទេ ។ ប៉ុន្តែព្រះវរបិតាសួគ៌នៅតែបានជួយនាងឲ្យរកឃើញរឿងសប្បាយៗដើម្បីធ្វើជាមួយគ្រួសាររបស់នាង—ហើយនោះគឺជារឿងដ៏សប្បាយដូចជាការពាក់អាវពណ៌ផ្កាឈូកសម្រាប់ការប្រកួត softball លើកដំបូងរបស់នាងដែរ ។ ●